ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពូ សុធីរៈ

* * *

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៦០/៩៦ ពម.ចសន.ប្រក

អនុញ្ញាតអោយលោក ឡាំ ប៊ុនហ៊ុយ បើកស្ថានីយ៍ផ្សាយ

សំលេង អេហ្វ អឹម ១០០,៥ មេហ្គាហឺត នៅស្រុក

កំពង់ចាម ខេត្តកំពង់ចាម

* * *

រដ្ឋមន្ត្រី ក្រសួងពតិមាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម សនរកម ០១៩៦-១៤ ចុះថ្ងៃទី ២៤ ខែ ០១ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពតិមាន
- យោងលិខិតស្នើសុំអនុញ្ញាតបើកស្ថានីយ៍វិទ្យុ អេហ្វអឹម ១០០,៥ មេហ្គាហឺត របស់លោក **ឡាំ ប៊ុនហ៊ុយ** ចុះថ្ងៃទី ២២ -៨ ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ឡាំ ប៊ុនហ៊ុយ** នាយកសាខាក្រុមហ៊ុនប្រេងឥន្ធនៈមិត្តភាព ប្រចាំ ខេត្តកំពង់ចាម បើកស្ថានីយ៍វិទ្យុផ្សាយសំឡេងអេហ្វអ៊ឹម ១០០,៥ មេហ្គាហឺត អនុភាពកំលាំងផ្សាយតិចជាង ឬអតិបរមា ០៥គ.វ និងកំពស់អង់តែនត្រឹមតែ ៩០ម៉ែត្រ នៅស្រុកកំពង់ចាម ខេត្តកំពង់ចាម ។

ប្រការ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ស្ថានីយ៍វិទ្យុនេះ ត្រូវគោរពតាមកិច្ចសន្យា និងច្បាប់ បញ្ញត្តិបទបញ្ជាឬសេចក្តីណែនាំខាងផ្នែកសោតទស្សន៍ទាំងឡាយនៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៣ : ក្នុងករណីមិនគោរពតាមប្រការ២ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤ : អគ្គនាយកវិទ្យុជាតិកម្ពុជា ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ-សោតទស្សន៍ នៃអគ្គនាយកដ្ឋាន រដ្ឋបាល ហិរញ្ញវត្ថុ មន្ទីរពតិមានខេត្ត កំពង់ចាម និងអាជ្ញាធរដែលពាក់ពន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ៥ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៦២/៩៦ ពម.ប្រក

អនុញ្ញាតអោយលោក BAYON YOUNG DAL សញ្ជាតិ

កូរ៉េ នាំចូលកាសែតជាភាសាកូរ៉េ ពីប្រទេសកូរ៉េ ខាងត្បូង

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ មាត្រា៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីរបបសារពតិមាននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខន.ស.រ កម ០៨៩៥-០៧ ចុះថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

– បានឃើញសំណើសុំរបស់លោក BAYON YOUNG DAL ជាប្រធានក្រុមហ៊ុន KORECAM IMEX CO.LTD ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក BAYON YOUNG DAL សញ្ជាតិ កូរ៉េ នាំចូលកាសែត ជាភាសាកូរ៉េពីប្រទេសកូរ៉េខាងត្បូង ឈ្មោះ -CHO SUN II-BO (DAILY),-DONG- AII-BO(DAILY) , និង HAN- KUK II-BO (DAILY)

-ក្នុងជំហានទី១ ចំនួនសរុប ៥០ច្បាប់

-ជំហានទី២ ចំនួននាំចូលនៃកាសែតខាងលើនេះ នឹងកើនឡើងពីរឬបីដងក្នុងមួយសប្តាហ៍ ចូលមករាជាណាចក្រកម្ពុជា តាមរយៈក្រុមហ៊ុន KORECAMIMEX Co LTD ដែលមានទីស្នាក់ការនៅ ផ្ទះលេខ ១៧២ អឺ០ ផ្លូវលេខ១២៨ សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយ ដែលផ្ទុយនឹងប្រកាសនេះ ត្រូវជូនដំណឹង មកក្រសួងពតិមានជាមុន ៥ថ្ងៃ ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ២ : លោក BAYON YOUNG DAL ត្រូវប្រគល់កាសែតមួយមុខៗ ចំនួន ០៦ច្បាប់ រៀង រាល់លេខ ដែលនាំចូលមកតំកល់ទុកជាឯកសារនៅក្រសួងពតិមាន ។

ប្រការ៣ : ការនាំចូលអត្ថបទនិងរូបភាពអាសអាភាសត្រូវហាមឃាត់ រាល់សកម្មភាពចែកផ្សាយត្រូវគោរពតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល២ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៦៣/៩៦ ពម.ប្រក

អនុញ្ញាតអោយប្តូរឈ្មោះកាសែតពី «ភ្នំពេញពិភពលោក»

មកកាសែត «ព្រឹត្តិការណ៍»វិញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ មាត្រា៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីរបបសារពតិមាននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខន.ស.រ កម ០៨៩៥-០៧ ចុះថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញសំណើសុំផ្លាស់ប្តូរឈ្មោះកាសែតរបស់លោក ពេជ រចនា ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះកាសែតពី «ភ្នំពេញពិភពលោក»មកកាសែត«ព្រឹត្តិការណ៍» វិញ ដោយមានលោកពេជ រចនា ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ៩៦ ផ្លូវ ១៩ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ។ ក្នុងករណីមាន ការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណ នៃកាសែតរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ៥ ថ្ងៃមកក្រសួងពតិមាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រម [illegible] កាសែត ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តអោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងស្នើប្រគល់កាសែតចំនួន៦ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពតិមាន ។

ប្រការ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ១ និងប្រការ២ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងចាងហ្វាងកាសែត «ព្រឹត្តិការណ៍ » ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល២ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្រ្តី
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៦៤/៩៦ ពម.ប្រក

អនុញ្ញាតអោយប្តូរឈ្មោះសារពត៌មាន «អរុណ» មកសារពត៌មាន «អ្នកតស៊ូ ដើម្បីលទ្ធិប្រជាធិបតេយ្យ» វិញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ មាត្រា៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស អោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០៨៩៥-០៧ ចុះថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញសំណើសុំប្តូរឈ្មោះសារពត៌មាន «អរុណ »មកសារពត៌មាន «អ្នកស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យ » របស់លោក សុខ សូផាត ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះសារពត៌មាន « អរុណ » មកសារពត៌មាន «អ្នកតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យ » បោះពុម្ពចែកផ្សាយ ដោយមានលោក សុខ សូផាត ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ៧ អឺ០ ក្រុម ៣៨ ផ្លូវ១៨៤ មណ្ឌលទី៦

សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណ នៃសារពត៌មានរបស់ខ្លួនត្រូវជូនដំណឹងជាមុន ៥ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចថ្មី ។

ប្រការ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តអោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងស្នើប្រគល់កាសែតចំនួន៦ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ១ និងប្រការ២ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងចាងហ្វាងសារពត៌មាន «អ្នកតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យ» ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល២ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
ខៀវ កាញារីទ្ធ

* * *

៥_ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៤៧/ បទ.ប្រក

ស្តីពីការតែងតាំងបរិគ្គាហកៈមន្ទីរប្រៃសណីយ៍ និង

ទូរគមនាគមន៍ខេត្តកំពត

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស រកម ០១៩៦-២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ និងប្រកាសអោយប្រើនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញប្រកាសលេខ ០៨២ ប្រក-បទ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំចរនាសម្ព័ន្ធ មន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍ ខ្សែបណ្តោយគ្រប់ ខេត្ត - ក្រុង
- ពិនិត្យសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងអ្នកស្រី **អ៊ុន សារី** ជាបរិគ្គាហកៈរងមន្ទីរប្រៃសណីយ៍ និងទូរគម នាគមន៍ ខេត្តកំពត ។

ប្រការ២ : បជិត្តាហកៈរងមានភារកិច្ចរួមសហការនិងទទួលខុសត្រូវលើការងារសេវាកម្ម អាជីវកម្មប្រៃសណីយ៍និងទូរគមនាគមន៍ ទូទាំងខេត្ត-ស្រុក ជូនមុខអោយក្រសួង ។

ប្រការ៣ : ខុទ្ទកាល័យ ,អគ្គិការដ្ឋាន នាយកដ្ឋានផែនការ គណនេយ្យ -ហិរញ្ញកិច្ច មន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តកំពត និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តន៍ តាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

សូ យុន

* * *

៦_ឧស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៧៥២/៩៦ អយក.ប្រក

ស្ដីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅវិជ្ជាជីវវិទ្យា

សំរាប់សិស្សថ្នាក់ទី៧

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤ -៩០ ចុះថ្ងៃ ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រម នស/រកម /០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជននិងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយក-ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំសុវជន និងកីឡា ស្ដីពីការបង្កើតគណៈកម្មការ កែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅផែនដីវិទ្យាសំរាប់សិស្សថ្នាក់ទី៧ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពសៀវភៅផែនដីវិទ្យាសំរាប់សិស្សថ្នាក់ទី៧ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការផែនដីវិទ្យា មធ្យមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំយុវជន និងកីឡា រៀបរៀងដោយអ្នកស្រី អ៊ូ វនី ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំណេះទូទៅ ។

ប្រការ២ : មន្ទីរ នាយកដ្ឋានបាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថាន ស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៧៥៣ អយក.ប្រ.ក.

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅផែនដីវិទ្យា

«សំរាប់គ្រូថ្នាក់ទី ៧ »

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតីចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រក.ត ១០៩៤–៩០ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រម នស.រកម .០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា ។
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំយុវជន និង កីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅផែនដីវិទ្យាសំរាប់គ្រូថ្នាក់ទី ៧ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅផែនដីវិទ្យាសំរាប់គ្រូថ្នាក់ទី ៧ «ដែលជាស្នាដៃនិពន្ធរបស់ គណៈកម្មការ ផែនដីវិទ្យាមធ្យមសិក្សានៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំយុវជន និង កីឡា និង រៀបរៀងដោយអ្នកស្រី អ៊ូ វ៉ាន់ឌី ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំណេះទូទៅ ។

ប្រការ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យ សិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និងត្រា

តុល ឡាះ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៧៥៤ អយក.ប្រ.ក.

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅសិក្សាសង្គម

«សំរាប់ថ្នាក់ទី ៦ »

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុង កម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស.រកម .០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំយុវជន និង កីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ

- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅសិក្សាសំរាប់គ្រូថ្នាក់ទី ៦ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៦

សំរេច

ប្រការ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅសិក្សាសង្គមសំរាប់គ្រូថ្នាក់ទី ៦ «ដែលជាស្នាដៃនិពន្ធ របស់គណៈកម្មការសិក្សាសង្គមបឋមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា និង រៀបរៀងដោយអ្នកស្រី **យិន ឌ័ានថា** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំណេះទូទៅ ។

ប្រការ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យ សិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និងត្រា

តុល ឡោះ

* * *

៧_ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៩៣៦ សនបឌ្ឋ

ស្តីពីបែបបទ និង លក្ខខ័ណ្ឌ ក្នុងការសុំបើក ឬបិទ ឬប្តូរទីតាំងនៃគ្រឹះស្ថាន អាហារំណានិហារំណាឱសថ

* * *

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស,រកម.០១៩៦,០៣ ចុះថ្ងៃទី ២៤_០១_៩៦

– បានឃើញច្បាប់ ស្ដីពីការគ្រប់គ្រងឱសថ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ជ ជស.រកម.០៦៩៦,០២ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦

– យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

សំរេច

ប្រការ១ : ការបើក ការបិទ និង ការប្ដូរទីតាំង នៃគ្រឹះស្ថាន អាហរ័ណ និហរ័ណឱសថ អាចប្រព្រឹត្តទៅបានលុះត្រាតែបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ២ : គ្រឹះស្ថាន អាហរ័ណនិហរ័ណឱសថ ព្រមទាំងសាខា ដែលបានទទួលការអនុញ្ញាតអោយបើកធ្វើអាជីវកម្មកន្លងមក ត្រូវបានរក្សាសិទ្ធិអោយបន្តអាជីវកម្មដដែល ដោយគ្រាន់តែមកបំពេញទំរង់បែបបទបន្ថែមនៅក្រសួងសុខាភិបាល តាមល័ក្ខខ័ណ្ឌក្នុងប្រកាសនេះ ។

ប្រការ៣ : អាចមានសិទ្ធិសុំបើក គ្រឹះស្ថាន អាហរ័ណនិហរ័ណឱសថ ឬសាខាបាន ឱសថការីទាំងពីរភេទ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម :

–មានសញ្ជាតិខ្មែរ

–មានសញ្ញាប័ត្រទទួលស្គាល់ពីក្រសួងសុខាភិបាល

–មិនដែលមានទោសពីបទល្មើសព្រហ្មទ័ណ្ឌណាមួយ

–មានសុខភាពគ្រប់គ្រាន់ អាចបំរើការងារបាន ។

ប្រការ៤ : សំណុំលិខិតសុំបើកគ្រឹះស្ថាន អាហរ័ណនិហរ័ណឱសថ ឬសាខាមាន :

១– ពាក្យសុំបើក មានបិទតែមប្រ៊ី ១.០០០៛ «មានគំរូ»

២– សញ្ញាប័ត្រឱសថការី ចេញដោយក្រសួងសុខាភិបាល ឬមានការទទួលស្គាល់ពីក្រសួងសុខាភិបាល

៣– ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន «មានគំរូ»

៤– វិញ្ញាបនប័ត្រសុខភាព ចេញដោយក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាល រាជធានីភ្នំពេញ ខេត្ត–ក្រុង

៥– គំនូសបំព្រួញទីតាំង ទីចាត់ការ និង ឃ្លាំងស្ដុក ដោយមានចំណារឯកភាពពីអាជ្ញាធរដែនដី

៦– លក្ខន្តិកៈក្រុមហ៊ុន

៧– លិខិតថ្កោលទោសដែលមានរយៈពេលមិនលើសពី ៣ ខែ

៨– រូបថតសាមីជន ៤×៦ សម ចំនួន ៥ សន្លឹក

សាមីជន ត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល «នាយកដ្ឋានឱសថ និង បរិក្ខារពេទ្យ» ក្រោយពីបានទទួលយោបល់ពីមន្ទីរសុខាភិបាល រាជធានីភ្នំពេញ ខេត្ត–ក្រុង ។

ប្រការ ៥ : ក្រសួងសុខាភិបាល និង ផ្តល់ចំលើយអំពីការសុំបើក ឬ ការសុំប្តូរទីតាំង នៃគ្រឹះស្ថានអាហារ័ណនិហារ័ណឱសថ ដល់សាមីជនយ៉ាងយឺតបំផុតក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃ បានទទួលសំណុំលិខិតនៅនាយកដ្ឋានឱសថ និង បរិក្ខារពេទ្យ ។

ប្រការ ៦ : ការសុំបើកសាខា នៃគ្រឹះស្ថាន អាហារ័ណនិហារ័ណឱសថ ត្រូវអនុវត្តតាមបែបបទ និងល័ក្ខខ័ណ្ឌដូចគ្នា និង ការសុំបើកគ្រឹះស្ថានដែរ ។

ប្រការ ៧ : ឱសថការីម្នាក់ៗ មានសិទ្ធិដាក់ពាក្យសុំបើក គ្រឹះស្ថាន អាហារ័ណនិហារ័ណឱសថ ឬ សាខាបានតែមួយកន្លែង និង មិនអាចប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតឡើយ ។

ប្រការ ៨ : ក្រសួងសុខាភិបាលរក្សាសិទ្ធិ ក្នុងការដកហូតវិញនូវលិខិតអនុញ្ញាតបើក ឬប្តូរទីតាំង នៃ គ្រឹះស្ថានអាហារ័ណនិហារ័ណឱសថ ឬសាខា ក្នុងករណីពិនិត្យឃើញថា :

១–សំណុំលិខិតមានលក្ខណៈក្លែងបន្លំ

២–ឬ សាមីជនរៀបចំគ្រឹះស្ថាន មិនសមស្របតាមល័ក្ខខ័ណ្ឌកំណត់

៣–ឬ សាមីជនជាប់ទោសពីបទល្មើសព្រហ្មទ័ណ្ឌ ។

ប្រការ ៩ : ការសុំប្តូរទីតាំងគ្រឹះស្ថាន អាហារ័ណនិហារ័ណឱសថ ឬសាខា ត្រូវបំពេញសំណុំលិខិតដូចខាង ក្រោម :

១–ពាក្យសុំប្តូរទីតាំងមានបិទតែមប្រិ៍ ១.០០០៛ «មានតំរូវ»

២–លិខិតអនុញ្ញាតបើក «ដើម»

៣–គំនូសបំព្រួញទីតាំងថ្មី ដែលមានចំណារឯកភាពពីអាជ្ញាធរដែនដី

៤–រូបថតរបស់សាមីជន ៤×៦ ចំនួន ៥ សន្លឹក

ប្រការ ១០: គ្រឹះស្ថាន អាហារ័ណនិហារ័ណឱសថ ឬសាខា ត្រូវដាច់ចេញពីកន្លែងស្នាក់នៅ មានអនាម័យស្អាតបាតទាំង ក្នុងទាំងខាងក្រៅ ព្រមទាំងមានការរៀបចំ សមស្របតាមការកំណត់ដូច ខាងក្រោម :

-ទីបាត់ការត្រូវមានការរៀបចំ តាមបែបផែនជាការិយាល័យ
-ឃ្លាំងត្រូវដាច់ពីកន្លែងស្នាក់នៅ និង មានទំហំយ៉ាងតិច ១២០ ម៣
-មានទូរ និង កំណល់គ្រប់គ្រាន់សំរាប់រៀបចំទុកដាក់ ផលិតផលឱសថ
-មានម៉ាស៊ីនត្រជាក់ និង កង្ហា គ្រប់គ្រាន់សំរាប់រក្សាសីតុណ្ហភាពក្នុងឃ្លាំងតាមលក្ខណៈបច្ចេកទេសឱសថសាស្ត្រ
-មានទូរ ពិសេសសំរាប់គ្រឿងញៀន និង/ឬជាតិពុល

ប្រការ ១១ : គ្រឹះស្ថាន អាហរ័ណនិហរ័ណឱសថ មានសិទ្ធិដូចតទៅ :

១-នាំចូល ឬនាំចេញនូវ :
-ឱសថគ្រប់ប្រភេទ សំរាប់វិស័យសុខាភិបាល និង បសុព្យាបាល
-ផលិតផលអនាម័យ ផលិតផលសំអាង ផលិតផលឌីយេតេទិក ដែលមានគុណភាពបង្ការ ឬព្យាបាលជម្ងឺ ឬអនាម័យខ្លួនប្រាណមនុស្ស
-សំភារៈបរិក្ខារពេទ្យ ទន្តពេទ្យ និង បសុពេទ្យ
-វត្ថុធាតុដើម សំភារៈវេចខ្ចប់ សំរាប់ផលិតកម្មឱសថ
-សំភារៈ ប្រតិករ សំរាប់មន្ទីរពិសោធន៍ វេជ្ជសាស្ត្រ ឱសថសាស្ត្រ

២-ស្តុកផលិតផលខាងលើ

៣-លក់ដុំ នូវផលិតផលខាងលើ ជូនដល់ឱសថស្ថានស្របច្បាប់

៤-បញ្ជាទិញផលិតផលឱសថ ពីគ្រឹះស្ថានផលិតផល ក្នុងនិងក្រៅប្រទេស

ប្រការ ១២ : សាខាគ្រឹះស្ថាន អាហរ័ណនិហរ័ណឱសថ មានសិទ្ធិដូចតទៅ :

ទទួលផលិតផលឱសថ ពីគ្រឹះស្ថានមេមកស្តុក និង លក់ដុំផលិតផលទាំងនោះជូន ដល់ឱសថស្ថានស្របច្បាប់ ។

ប្រការ ១៣ : បែបបទអាជីវកម្ម :

១-ក្នុងគ្រឹះស្ថាន អាហរ័ណនិហរ័ណឱសថ ឬសាខា ឱសថការី ត្រូវទទួលខុសត្រូវគ្រប់ គ្រងសកម្មភាពបច្ចេកទេសក្នុងគ្រឹះស្ថានរបស់ខ្លួន ។

២-គ្រឹះស្ថាន អាហរ័ណនិហរ័ណឱសថ ឬសាខា ត្រូវធានាចំពោះគុណភាព និងសុវត្ថិភាពឱសថរបស់ខ្លួនដែលបានចែកចាយជូនឱសថស្ថាន ។

ក្នុងករណីមានការចោទប្រកាន់ ពីក្រសួងមានសមត្ថកិច្ចបញ្ជាអោយដកហូតទំនិញពីទីផ្សារនោះ គ្រឹះស្ថានត្រូវប្រមូលជាបន្ទាន់ នូវផលិតផលមិនត្រឹមត្រូវទាំងនោះវិញ ។

៣-ផលិតផលចែកចាយ ត្រូវមានរយៈពេលប្រើយ៉ាងតិច ៦ ខែ មុនផុតកំណត់ពេលប្រើប្រាស់ ។

៤-ការចែកចាយត្រូវអនុវត្តតាមប្រកាសជូនដំណឹង ឬតាមការបញ្ជាទិញរបស់ឱសថស្ថាន ។

៥-នៅលើប័ណ្ណបញ្ជាទិញ ឬប័ណ្ណបញ្ចូល ឬបញ្ចេញ ឬវិក្កយប័ត្រទំនិញ ត្រូវមានចុះហត្ថលេខា និង ឈ្មោះរបស់ឱសថការីទទួលខុសត្រូវ ។

ប្រការ ១៤ : បញ្ញត្តិហាមឃាត់ :

១-ហាមលក់រាយ ឬលក់ដុំជូនអតិថិជនក្រៅពីឱសថស្ថាន

២-ហាមនាំចូលឬចែកចាយឬស្តុកឱសថដែលគ្មានទិដ្ឋាការ-បញ្ជីការឱសថ ឬឱសថដែល ក្រសួងសុខាភិបាលបានហាមឃាត់ ឱសថក្លែងក្លាយ ឬឱសថផុតកំណត់ពេលប្រើប្រាស់ ។

៣-ហាមលក់ខុសពីតំលៃដែលរដ្ឋបានកំណត់

៤-ហាមស្តុកឱសថក្នុងឃ្លាំងដែលគ្មាន ការអនុញ្ញាតពីក្រសួងសុខាភិបាល

៥-ហាមប្រកបអាជីវកម្មផ្សេងក្រៅពីឱសថ នៅក្នុងគ្រឹះស្ថាន អាហរ័ណ និហរ័ណ ឬ សាខា ។

ប្រការ ១៥ : ក្នុងករណីអវត្តមានរបស់ឱសថការីទទួលខុសត្រូវ គ្រឹះស្ថានអាហរ័ណនិហរ័ណ ឱសថ ឬសាខា ត្រូវមានឱសថការីមួយរូបទៀតជំនួស ។

ឱសថការីជំនួសមានការទទួលខុសត្រូវចំពោះមុខច្បាប់ ។

ការជំនួសអាចប្តូរជាថ្មីបានតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ ១៦ : រយៈកាលនៃការជំនួស មិនអាចលើសពី ១ ឆ្នាំ បានទេ ។ ក្នុងករណីចាំបាច់ និងមានមូលហេតុសមស្រប រយៈកាលនៃការកំណត់ខាងលើអាចពន្យារបាន១ ឆ្នាំ ទៀតតាមសេចក្តីសំរេចរបស់ក្រសួងសុខាភិបាល ។

ប្រការ ១៧ :ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានឱសថ និង បរិក្ខារពេទ្យ និង មន្ទីរសុខាភិបាលរាជធានីភ្នំពេញ ខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងខ្លួន ។

ប្រការ ១៨ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារ ផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១៩ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ឈា ថាំង

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ៩៣៧ សនបឡ

ស្តីពីបែបបទ និង លក្ខខ័ណ្ឌ ក្នុងការសុំបើក ឬបើក

ឬ ប្តូរទីតាំង នៃគ្រឹះស្ថានលក់ឱសថ

* * *

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ - ០១ - ១៩៩៦
- បានឃើញច្បាប់ ស្តីពីការគ្រប់គ្រងឱសថ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ - មិថុនា - ១៩៩៦
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

សំរេច

ប្រការ ១.~ គ្រឹះស្ថានលក់ឱសថចែកចេញជា ៤ ប្រភេទ ÷

–ឱសថស្ថានគ្រប់គ្រងដោយឱសថការី

–ឱសថស្ថានរង « ក » គ្រប់គ្រងដោយឱសថការីមធ្យម

–ឱសថស្ថានរង «ខ»គ្រប់គ្រងដោយមន្ត្រីសុខាភិបាលចូលនិវត្តន៍ដែលមានកំរិតបច្ចេកទេសចាប់ពី គិលានុបដ្ឋាកមធ្យមឡើងទៅ

–អាគារលក់ឱសថបូរាណគ្រប់គ្រងដោយគ្រូបូរាណ

បែបបទ និង លក្ខខ័ណ្ឌក្នុងការបើក និងពាណិជ្ជកម្មឱសថបូរាណត្រូវកំណត់ក្នុងប្រកាសមួយដោយឡែក ។

ប្រការ ២.~ ការបើក ការបិទ ការប្តូរទីតាំង និងការផ្ទេរមូលនិធិពាណិជ្ជកម្ម នៃឱសថស្ថាន និងឱសថស្ថានរងអាចប្រព្រឹត្តទៅបាន លុះត្រាតែបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ ៣.~ ឱសថស្ថាន ឱសថស្ថានរង ដែលបានទទួលការអនុញ្ញាតអោយបើក តាមខ្លឹមសារប្រកាសលេខ ១១៥ សនបឱ ចុះថ្ងៃទី ២៥ កុម្ភៈ ១៩៩១ ត្រូវបានរក្សាសិទ្ធិធ្វើពាណិជ្ជកម្ម ផដែល ។

–ក្នុងករណីមានការសុំប្តូរទីតាំង ឬ សុំផ្ទេរមូលនីធិពាណិជ្ជកម្មនៃឱសថស្ថាន ឱសថស្ថានរង ខាងលើត្រូវអនុវត្តតាមលក្ខខ័ណ្ឌថ្មីនៃប្រកាសនេះ ។

ប្រការ ៤.~ ចំនួនឱសថស្ថាន ត្រូវកំណត់តាមចំនួនប្រជាពលរដ្ឋក្នុងសង្កាត់ ឃុំជាមូលដ្ឋានតាមសមាមាត្រប្រជាពលរដ្ឋយ៉ាងតិច ៣.០០០នាក់ សំរាប់ឱសថស្ថានមួយកន្លែងក្នុងរាជធានីភ្នំពេញ និង យ៉ាងតិច ២.០០០ នាក់ សំរាប់ឱសថស្ថានមួយកន្លែងក្នុងខេត្ត -ក្រុង ។

ក្រសួងសុខាភិបាលនឹងប្រកាសអំពីការបែងចែកចំនួនឱសថស្ថានតាមសង្កាត់ ឃុំ នីមួយៗ ក្នុង ១ ឆ្នាំ ១ ដង ក្នុងអាទិត្យទី១ នៃខែ មករា រៀងរាល់ឆ្នាំ ។

ប្រការ ៥.~ ទីតាំងឱសថស្ថាន ឱសថស្ថានរង ត្រូវកំណត់តាមលក្ខខ័ណ្ឌ ដូចខាងក្រោម :

[illegible] អាចមានទីតាំងនៅគ្រប់ទីកន្លែង ក្នុងព្រះរាជាណាចក្រកម្ពុជា

-ឱសថស្ថានរង «ក» អាចមានទីតាំងនៅតាមកន្លែងណាដែលឱសថស្ថានមានចំនួន មិនទាន់គ្រប់គ្រាន់តាម សមាមាត្រកំណត់ក្នុងប្រការ ៤ ។

–ឱសថស្ថានរង«ខ» អាចមានទីតាំងនៅតាមសង្កាត់ ឃុំណា ដែលឱសថស្ថាន និង ឱសថស្ថានរង «ក» មានចំនួនមិនទាន់គ្រប់គ្រាន់តាមសមាមាត្រកំណត់ ។

ប្រការ ៦.~ អាចមានសិទ្ធិសុំបើកឱសថស្ថាន - ឱសថស្ថានរងបាន

ឱសថការី - ឱសថការីមធ្យម មន្ត្រី សុខាភិបាលចូលនិវត្តន៍ ទាំងពីរភេទ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម ÷

–មានសញ្ជាតិខ្មែរ

–មានសញ្ញាប័ត្រទទួលស្គាល់ពីក្រសួងសុខាភិបាល

–មិនដែលមានទោសពីបទល្មើសព្រហ្មទណ្ឌណាមួយ

–មានសុខភាពគ្រប់គ្រាន់អាចបំរើការងារបាន

ប្រការ ៧.~ សំណុំលិខិតសុំបើកឱសថស្ថាន - ឱសថស្ថានរងមាន :

១–ពាក្យសុំបើកឱសថស្ថាន - ឱសថស្ថានរង មានបិទតែមប្រ៍ ១.០០០រៀល «មានគំរូ»

២–សញ្ញាប័ត្រឱសថការី ឬ ឱសថការីមធ្យមចេញដោយក្រសួង សុខាភិបាល ឬមានការទទួលស្គាល់ពីក្រសួងសុខាភិបាល

៣–សេចក្តីសំរេចចូលនិវត្តន «ចំពោះមន្ត្រីសុខាភិបាលចូលនិវត្តន៍»

៤–ជីវប្រវត្តិសង្ខេបរបស់សាមីជន «មានគំរូ»

៥–វិញ្ញាបនបត្រសុខភាពចេញដោយក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាល រាជធានី ខេត្ត - ក្រុង

៦–លិខិតថ្កោលទោស ដែលមានរយៈពេលមិនលើសពី បីខែ

៧–គំនូសបំព្រួញទីតាំង ដោយមានចំណារឯកភាពពីអាជ្ញាធរដែនដី

៨–រូបថតសាមីជន ៤ × ៦ សម. ចំនួន [illegible] សន្លឹក ។

សាមីជនត្រូវបំពេញសំណុំលិខិត ខាងលើហើយបញ្ជូនមកក្រសួងសុខាភិបាល «នាយក ដ្ឋានឱសថ និង បរិក្ខារពេទ្យ»
ក្រោយពីបានទទួលយោបល់ពីមន្ទីរសុខាភិបាលរាជធានី _ខេត្ត_ក្រុង ។

ប្រការ ៨.~ ក្នុងករណីចំនួនអ្នកសុំបើកឱសថស្ថាន - ឱសថស្ថានរងច្រើនជាងចំនួនទីតាំងកំណត់ ក្រសួងនឹងផ្តល់អាទិភាពចំពោះសាមីជនណាដែលបានដាក់ពាក្យសុំបើក ដែលមានសំណុំលិខិត ត្រឹមត្រូវតាមការកំណត់ក្នុងប្រការ ៧ មកនាយកដ្ឋានឱសថ និង បរិក្ខារពេទ្យមុនគេ ។

ប្រការ ៩.~ ក្រសួងសុខាភិបាលនឹងផ្តល់ចំលើយអំពីការសុំបើក ការប្តូរទីតាំង និងការផ្ទេរមូលនិធិពាណិជ្ជកម្មនៃឱសថស្ថាន-ឱសថស្ថានរងដល់សាមីជនយ៉ាង យឺតបំផុតក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសំណុំលិខិតនៅនាយកដ្ឋាន ឱសថ និងបរិក្ខារពេទ្យ ។

ប្រការ ១០.~ ឱសថការី - ឱសថការីមធ្យម ឬមន្ត្រីសុខាភិបាលចូលនិវត្តន៍មួយរូប មានសិទ្ធិដាក់ពាក្យសុំបើក ឱសថស្ថាន - ឱសថស្ថានរង បានតែមួយកន្លែង និងមិនអាចប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេង ទៀតឡើយ ។

ប្រការ ១១.~ ក្រោយពីបានទទួលការអនុញ្ញាតបើកពីក្រសួងសុខាភិបាល សាមីជនត្រូវបើកទ្វារបំរើ សាធារណៈជនយ៉ាងយឺតបំផុតក្នុងរយៈពេល ៣ ខែ ។ ផុតកំណត់ខាងលើ បើឱសថស្ថាន - ឱសថស្ថានរងគ្មានដំណើរការទេនោះ លិខិតអនុញ្ញាតត្រូវចាត់ទុកជាមោឃៈដោយស្វ័យប្រវត្តិតាមសេចក្តីប្រកាសរបស់ក្រសួងសុខាភិបាល ។ ក្នុងករណីមានមូលហេតុសមស្រប រយៈកាលកំណត់ខាងលើអាចពន្យារពេលបាន ៣ ខែទៀត ហើយបានតែមួយដងគត់ តាមសំណើរបស់សាមីជន ។

ប្រការ ១២.~ ក្រសួងសុខាភិបាលរក្សាសិទ្ធិក្នុងការដកហូតវិញនូវលិខិតអនុញ្ញាតបើក ប្តូរទីតាំង ឬផ្ទេរមូលនិធិ ពាណិជ្ជកម្មនៃឱសថស្ថាន - ឱសថស្ថានរង ក្នុងករណីពិនិត្យឃើញថា :

១–សំណុំលិខិតមានលក្ខណៈក្លែងបន្លំ

២–ឬសាមីជនរៀបចំ ឱសថស្ថាន - ឱសថស្ថានរង មិនស្របតាមល័ក្ខខ័ណ្ឌកំណត់

៣–ឬសាមីជនជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ

៤–ឬ ឱសថស្ថាន - ឱសថស្ថានរងគ្មានដំណើរការក្នុងរយៈពេល ៣ ខែ ឬ ៦ ខែ តាមការកំណត់ក្នុងប្រការ ១១ ។

ប្រការ ១៣.~ការសុំប្តូរទីតាំងឱសថស្ថាន - ឱសថស្ថានរង ពីកន្លែងមួយ ទៅកន្លែងមួយទៀតក្នុងសង្កាត់ដដែល ឬពីសង្កាត់មួយទៅសង្កាត់ផ្សេងមួយទៀត អាចអនុញ្ញាតបានលុះត្រាតែការផ្លាស់ប្តូរនោះ មិនបណ្តាល អោយលើសចំនួនឱសថស្ថាន ដែលបានកំណត់ក្នុងប្រការ ៤ ហើយឱសថស្ថាន-ឱសថស្ថានរង នោះបានបើកទ្វារបំរើសាធារណជនអស់រយៈពេលលើសពី ៦ ខែមកហើយ ។

ប្រការ ១៤.~សំណុំលិខិតសុំប្តូរទីតាំងមាន :

១–ពាក្យសុំប្តូរទីតាំងមានបិទតែមប្រ៊ី ១.០០០៛០០ «មានគំរូ »

២–លិខិតអនុញ្ញាតបើក «ដើម »

៣–គំនូសបំព្រួញទីតាំងថ្មី ដែលមានការឯកភាពពីអាជ្ញាធរដែនដី

៤–រូបថតសាមីជន ៤ × ៦ សម ចំនួន ៥ សន្លឹក

សាមីជនត្រូវបំពេញលិខិតខាងលើ ហើយបញ្ជូនមកនាយកដ្ឋានឱសថ និងបរិក្ខារពេទ្យ ក្រោយពីមានយោបល់ពីមន្ទីរសុខាភិបាលរាជធានី ខេត្ត - ក្រុង ។

ប្រការ ១៥.~ការផ្ទេរមូលនិធិពាណិជ្ជកម្ម នៃឱសថស្ថាន - ឱសថស្ថានរង ពីជនម្នាក់ទៅជនម្នាក់ផ្សេងទៀតអាចអនុញ្ញាតបានលុះត្រាតែសាមីជនបានបំពេញល័ក្ខខ័ណ្ឌទាំង ៣ ខាងក្រោមនេះ :

១–ការផ្ទេរនោះមិនបណ្តាលអោយលើស ចំនួនឱសថស្ថាន - ឱសថស្ថានរង ដែលបានកំណត់ក្នុងប្រការ ៤

២– ឱសថស្ថាន - ឱសថស្ថានរងនោះ បានបើកទ្វារបំរើសាធារណជនអស់រយៈពេលលើសពី ១ ឆ្នាំមកហើយ

៣–មានការឯកភាពគ្នាជាលាយលក្ខអក្សររវាងអ្នកផ្ទេរចេញនិងអ្នកទទួល

ប្រការ ១៦.~ សំណុំលិខិតផ្ទេរមូលនិធិរួមមាន ÷

១–ពាក្យសុំប្តូរទីតាំងមានបិទតែមប្រ៊ី ១.០០០៛០០ «មានគំរូ»

២–កិច្ចព្រមព្រៀងផ្ទេរមូលនិធិ«មានគំរូ»

៣–លិខិតអនុញ្ញាតបើក «ដើម»

៤–សញ្ញាប័ត្រ ឱសថការី ឬឱសថការីមធ្យម ចេញដោយក្រសួងសុខាភិបាល ឬមានការទទួលស្គាល់ពីក្រសួងសុខាភិបាល របស់ជនទទួលមូលនិធិ

៥–សេចក្តីសំរេចចូលនិវត្តន៍ «ចំពោះមន្ត្រីសុខាភិបាលចូលនិវត្តន៍ » របស់អ្នកទទួលមូលនិធិ

៦–ជីវប្រវត្តិសង្ខេបរបស់អ្នកទទួលមូលនិធិ

៧–វិញ្ញាបនប័ត្រសុខភាពរបស់អ្នកទទួលមូលនិធិ

៨–លិខិតថ្កោលទោស ដែលមានរយៈពេលមិនលើសពី ៣ ខែ

៩–រូបថត ៤ × ៦ សម ចំនួន ៥ សន្លឹក របស់អ្នកទទួលមូលនិធិ

សាមីជនត្រូវបំពេញសំណុំលិខិតខាងលើហើយ បញ្ជូនមកនាយកដ្ឋានឱសថ និង បរិក្ខារពេទ្យ ក្រោយពីបានទទួលយោបល់ពីមន្ទីរសុខាភិបាលរដ្ឋធានី ខេត្ត - ក្រុង ។

ប្រការ ១៧.–អំពីការរៀបចំ គ្រឹះស្ថានលក់ឱសថ :

ឱសថស្ថាន - ឱសថស្ថានរងត្រូវដាច់ចេញពីការស្នាក់នៅ មានអនាម័យស្អាតបាតទាំងខាងក្នុងទាំងខាងក្រៅ និង មានការរៀបចំសមស្របតាមការកំណត់ដូចខាងក្រោម :

១–មានផ្ទៃក្រឡាអាជីវកម្មយ៉ាងតិច ២០ $ម^2$ សំរាប់ឱសថស្ថាន និង ១៦ $ម^2$ សំរាប់ ឱសថស្ថានរង

២–មានផ្លាកសញ្ញាឱសថស្ថាន - ឱសថស្ថានរង «មានគំរូ»

៣–មានទូកញ្ចក់ស្អាតបាតពណ៌ស គ្រប់គ្រាន់សំរាប់តាំងឱសថ បរិក្ខារពេទ្យ

៤–មានទូរបញ្ជរ សំរាប់បេឡាការី និងអ្នកប្រគល់ឱសថ

៥–មានទូរថ្នាំពិសេសសំរាប់ស្តុកគ្រឿងញៀន និង ជាតិពុល

៦–មានទូរទឹកកកសំរាប់ស្តុកឱសថ ដែលទាមទារការថែទាំត្រឹមត្រូវតាមសីតុណ្ហភាពកំណត់

៧–មានឃ្លាំងស្តុកឱសថ

៨–បន្ទប់ផ្សំឱសថប្រសិនបើមាន ត្រូវរៀបចំអោយបានសមស្របតាមបច្ចេកទេស ឱសថសាស្ត្រ ។

ប្រការ ១៨.– ឱសថស្ថាន - ឱសថស្ថានរងអាចតាំងលក់នូវប្រភេទទំនិញដូចខាងក្រោម :

១–ឱសថសំរាប់វិស័យសុខាភិបាល និង បសុព្យាបាល

២–ផលិតផលអនាម័យ ផលិតផលសំអាង ផលិតផលឌីយេតេទិក ដែលមានគុណភាពបង្ការ ឬព្យាបាលជំងឺ ឬអនាម័យខ្លួនប្រាណមនុស្ស

៣–សំភារៈបរិក្ខារពេទ្យ ទន្តពេទ្យ និង បសុពេទ្យ

៤–សំភារៈ ប្រតិករ សំរាប់មន្ទីរពិសោធន៍ វេជ្ជសាស្ត្រ - ឱសថសាស្ត្រ

ប្រការ ១៩.– ឱសថស្ថានមានសិទ្ធិដូចតទៅ :

១–លក់ដុំ និង លក់រាយ នូវផលិតផលដូចមានចែងក្នុងប្រការ ១៨ ជូនដល់ :

- អង្គភាពសេវាសុខាភិបាលរដ្ឋ ឬឯកជនដែលស្របច្បាប់សំរាប់ប្រើប្រាស់ក្នុងវិជ្ជាជីវៈ ផ្ទាល់ខ្លួនដែលមានជាអាទិ៍ មន្ទីរពេទ្យ ពហុព្យាបាល សម្ភព មន្ទីរពិនិត្យពិគ្រោះជំងឺ មន្ទីរពិនិត្យព្យាបាលជំងឺមាត់ ធ្មេញមន្ទីរ ពិសោធន៍ និងឱសថស្ថានរង
- អតិថិជនសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន

២–ផ្សំឱសថមួយចំនួនតាមវេជ្ជបញ្ជា ឬតាមក្បួនឱសថសាស្ត្រ

៣–បញ្ជាទិញ ផលិតផល ពីគ្រឹះស្ថានផលិតឱសថ ឬគ្រឹះស្ថានអាហរ័ណនីហរ័ណឱសថ ។

ប្រការ ២០.– ឱសថស្ថានរងមានសិទ្ធិដូចតទៅ :

១–លក់រាយ នូវផលិតផលដូចមានចែងក្នុងប្រការ ១៨ តាមបញ្ជីកំណត់របស់ក្រសួងសុខាភិបាលជូនដល់អតិថិជនសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន

២–បញ្ជាទិញផលិតផលឱសថពីឱសថស្ថាន ។

ប្រការ ២១.~ បែបបទពាណិជ្ជកម្ម :

១–ក្នុងឱសថស្ថាន - ឱសថស្ថានរង ត្រូវមានវត្តមានឱសថការី ឱសថការីមធ្យម ឬមន្ត្រីសុខាភិបាលទទួលខុសត្រូវ ដើម្បីគ្រប់គ្រងសកម្មភាពក្នុងគ្រឹះស្ថានលក់ឱសថរបស់ខ្លួន ។

២–អ្នកលក់ត្រូវពាក់អាវពេទ្យពណ៌ស (Blouse) និង មានដាក់ឈ្មោះ ។

-អ្នកលក់ត្រូវចេះអាន សរសេរ និងចេះបកស្រាយវេជ្ជបញ្ជា

៤–ត្រូវចុះឈ្មោះឱសថដែលផ្តល់ជូនអតិថិជនក្នុងសៀវភៅលក់ប្រចាំថ្ងៃ

៥–ការលក់ឱសថដែលផ្សំឡើងដោយជាតិពុលក្នុងបញ្ជី១ ឬបញ្ជី២ ឬគ្រឿងញៀន ត្រូវអនុវត្តអោយបានត្រឹមត្រូវតាមអនុក្រឹត្យ ស្តីពីការគ្រប់គ្រងជាតិពុលសំរាប់វិស័យសុខាភិបាល ។

៦–ការផ្តល់ឱសថតាមវេជ្ជបញ្ជា ត្រូវពិនិត្យអោយបានច្បាស់អំពីឈ្មោះនិង ហត្ថលេខារបស់គ្រូពេទ្យព្យាបាល ឈ្មោះចំនួនកំរិតរបៀបប្រើឱសថ ។ ប្រសិនបើពិនិត្យឃើញមានការកែ ឬ គោសលុប ឬ ប្រើលើសកំរិតឬប្រើខុសក្បួនវេជ្ជសាស្ត្រត្រូវអោយអតិថិជនទៅសុំការបញ្ជាក់សាជាថ្មីពីគ្រូពេទ្យព្យាបាល ដោយមិនត្រូវលក់ទាំងប្រថុយប្រថានឡើយ ។

៧–នៅលើវេជ្ជបញ្ជាដែលបានផ្តល់ឱសថរួចហើយ ត្រូវមានបោះត្រាឱសថស្ថាន ឬឱសថស្ថានរង និង មានចុះថ្ងៃខែបញ្ចេញលក់ផង ។

ប្រការ ២២.~ បញ្ញត្តិហាមឃាត់ :

១–ហាមលក់ឱសថដែលមានប្រភពមិនស្របច្បាប់ ។

២–ហាមលក់ឱសថដែលក្រសួងសុខាភិបាលបានហាមឃាត់ ។

៣–ហាមលក់ឱសថផុតកំណត់ប្រើប្រាស់ ។

៤–ហាមលក់ឱសថខុសពីតំលៃដែលរដ្ឋបានកំណត់ ។

៥–ហាមតាំងលក់ផលិតផលដែលគ្មានកំណត់ក្នុងប្រការ ១៨ ។

៦–ហាមប្រកបអាជីវកម្មផ្សេងទៀត ក្នុងគ្រឹះស្ថានលក់ឱសថ ។

ប្រការ ២៣.~ ក–ក្នុងករណីអវត្តមានរបស់ឱសថការី ឬឱសថការីមធ្យម ឬមន្ត្រីសុខាភិបាល ទទួលខុសត្រូវ ដែលមានរយៈពេលតិចជាង ៣ ខែ ឱសថស្ថាន - ឱសថស្ថានរង ត្រូវមានអ្នកទទួលខុសត្រូវ ជំនួសដែលមានលក្ខណៈសម្បត្តិជា :

- ឱសថការីឧត្តម ឬនិស្សិតឱសថសាស្ត្រឆ្នាំទី ៥ ចំពោះឱសថស្ថាន
- ឱសថការីមធ្យម ឬនិស្សិតឱសថសាស្ត្រមធ្យមឆ្នាំទី ៤ ចំពោះឱសថស្ថានរង«ក»
- មន្ត្រីសុខាភិបាលចូលនិវត្តន៍ ដែលមានកំរិតបច្ចេកទេសសមស្រប ចំពោះឱសថស្ថានរង «ខ»

ខ–ក្នុងករណីអវត្តមានដែលមានរយៈពេលពី ៣ ខែទៅ ១ ឆ្នាំ អ្នកទទួលខុសត្រូវជំនួសត្រូវ មានលក្ខណៈសម្បត្តិជា :

- ឱសថការីឧត្តម ចំពោះឱសថស្ថាន
- ឱសថការីមធ្យម ចំពោះឱសថស្ថានរង«ក»
- មន្ត្រីសុខាភិបាលចូលនិវត្តន៍ ដែលមានកំរិតបច្ចេកទេសសមស្រប ចំពោះឱសថស្ថានរង «ខ»

ការជំនួសអាចចូលជាធរមានបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ ២៤.~រយៈកាលនៃការជំនួសមិនអាចលើសពី ១ ឆ្នាំបានទេ ។ ក្នុងករណីចាំបាច់ និងមានមូលហេតុ សមស្របរយៈកាលនៃការកំណត់ខាងលើអាចពន្យារបានមួយឆ្នាំទៀត តាម សេចក្តីសំរេចរបស់ក្រសួងសុខាភិបាល ។

ប្រការ ២៥.~ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានឱសថនិងបរិក្ខារពេទ្យ និងមន្ទីរសុខាភិបាលរាជធានី ខេត្ត - ក្រុង មានភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងខ្លួន ។

ប្រការ ២៦.~ បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ២៧.~ ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ហត្ថលេខា និង ត្រា

វេជ្ជ. ឈា ថាំង

* * *

៨_ទីស្តីការរដ្ឋមន្ត្រីក្រសួងបរិស្ថាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ១៤៣៥ មស្ថ

ស្តីពីការទទួលស្គាល់ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ ១១ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦/២១ ស្តីពីការប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងបរិស្ថាន ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- យោងលិខិតលេខ ១៤ ដក កច ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ១៩៩៦ របស់អភិបាលខេត្ត
- ពិនិត្យលើការចាំបាច់របស់មន្ទីរបរិស្ថានខេត្តកំពង់ចាម

សំរេច

ប្រការ ១.~ ទទួលស្គាល់ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ដែលផ្ទេរមកពីសាលាស្រុក អោយទៅបំរើការងារនៅមន្ទីរបរិស្ថានខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ÷

– ស្រុកកំពង់ចាម :

១– លោក ឆោត សារឿន

២– លោក ហ៊ុន ស

៣– លោក មាឃ សំអុល

– ស្រុកព្រៃឈរ :

១– លោក ជុន សារិន

២– លោក ឈេង លឿង

៣– លោក ពូ ឌល

– ស្រុកបារាយ :

១– លោក សរ សុន

២– លោក ក្រាម ប៊ុនធី

៣– លោក សេង សុខឡី

– ស្រុកស្ទឹងត្រង់ :

១– លោក សេង អ៊ា

២– លោក ចាប ទន្ទី

៣– លោក ខាន ឈាក់

– ស្រុកអូរាំងឪ :

១– លោក ម៉េង ហុង

២– លោក អ៊ុំ សុវណ្ណារា

៣– លោក សេង វណ្ណា

– ស្រុកតំបែរ :

១– លោក សេក ប៊ុនហេង

២– លោក រស់ សារុន

៣– លោក ហ៊ួយ សុខ

– ស្រុកស្រីសន្ធរ :

១– លោកស្រី អ៊ី សុខុម

២– លោក ឆេព សុវណ្ណ

– ស្រុកកំពង់សៀម :

១– លោក មុំ ស៊ួន

២– លោក លឹម ស៊ីថា

– ស្រុកត្បូងឃ្មុំ :

១– លោក ម៉ៅ ម៉េងជាង

– ស្រុកពញាក្រែក :

១– លោក ឈុម ហ៊ាង

២– លោក ឡេង ចាន់ថន

– ស្រុកកោះសូទិន :

១– លោក ហ៊ូ ឈាងសេង

២– លោក រ៉ាម ស៊ាមលី

៣– លោកស្រី ស៊ាន សុខា

– ស្រុកក្រូចឆ្មារ :

១– លោក ជា ម៉ឿន

២– លោក ប្រាក់ សង្វាត

៣– លោក ម៉ឹម ស៊ីសង្ហា

– ស្រុកចំការលើ :

១– លោក ជា ឌី

២– លោក ជួ ចាន់ថុល

– ស្រុកជើងព្រៃ :

១– លោក ពៅ ម៉ួយ

២- លោក ស្រ៊ុន ការាយ

- ស្រុកកងមាស :

១- លោក ម៉ុល នីរមិត្ត

២- លោក សោម មុន្នី

ប្រការ ២.~ ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួនមន្ទីរបរិស្ថានខេត្តកំពង់ចាម ជានាផ្តត់ផ្គង់ បន្តបន្ទាប់ពីវិញ្ញាបនប័ត្រផ្ទេរប្រាក់ពីអង្គភាពដើម ។

ប្រការ ៣.~ អគ្គនាយក ខុទ្ទកាល័យ មន្ទីរក្រសួងអង្គភាពដែលពាក់ព័ន្ធ នឹងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត ម៉ុក ម៉ារ៉េត

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ១៤៨១ បស្ថ

ស្តីពីការតែងតាំង និង តម្លើងឋានៈ មន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦/២១ ស្តីពីការប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

– យោងលិខិតលេខ ២៤២ សណ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៦ របស់អភិបាលខេត្តកណ្ដាល

– ពិនិត្យលើការចាំបាច់របស់មន្ទីរបរិស្ថានខេត្តកណ្ដាល

សំរេច

ប្រការ ១.~ តែងតាំងលោក **គិន ជាង** បច្ចុប្បន្នជាប្រធានការិយាល័យផែនការបរិស្ថាន និងត្រួតត្រាការ ប្រតិបត្តិ ជាអនុប្រធានមន្ទីរបរិស្ថានខេត្តកណ្ដាល ។

ប្រការ ២.~ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួនត្រូវបានកែសំរួលទៅតាមតួនាទី និង ភារកិច្ចថ្មី ។

ប្រការ ៣.~ អគ្គនាយក ខុទ្ទកាល័យ មន្ទីរ ក្រសួង អង្គភាពដែលពាក់ព័ន្ធ និង លោក **គិន ជាង** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

បណ្ឌិត **ម៉ុក ម៉ារ៉េត**

* * *

៩_ឯកសារក្រសួងធម្មការ និង សាសនា

សេចក្ដីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៩៦

សេចក្ដីសំរេច លេខ : ១៧០/៩៦ កធស.

ស្ដីពីការអនុញ្ញាតអោយសាងសង់វិហារឥស្លាម

ភូមិកំពង់កណ្ដាល ឃុំជុំក្រៀលស្រុកកំពត ខេត្តកំពត

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាម ព្រះរាជក្រមលេខ នស.រកម ០១៩៦ - ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំនិង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញសំណើសុំសាងសង់វិហារឥស្លាមភូមិកំពង់កណ្តាល ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១.- អនុញ្ញាតអោយសាងសង់វិហារឥស្លាមនៅលើកន្លែងចាស់ ភូមិកំពង់កណ្តាល ឃុំជុំគ្រៀល ស្រុកកំពត ខេត្តកំពត ។

ប្រការ ២.- វិហារឥស្លាមនេះត្រូវបានអនុញ្ញាតអោយសាសនិកនៃឥស្លាមគោរពប្រតិបត្តិ ផ្សព្វផ្សាយតាមជំនឿ ប្រពៃណីសាសនាឥស្លាម ដោយអនុវត្តអោយបានត្រឹមត្រូវតាមគម្ពីរគួរអាន និង ហាទេស ។

ប្រការ ៣.- វិហារឥស្លាមនេះត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិទាំងឡាយរបស់ក្រសួងធម្មការ និង សាសនា ។ មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិ សេរីភាពជំនឿសាសនាដទៃ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងទំនាក់ទំនងអោយបានល្អប្រសើរ ជាមួយរដ្ឋអំណាច និងស្ថាប័នពាក់ព័ន្ធ ។

ប្រការ ៤.- រាល់ការអនុវត្តដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥.- នាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ច នាយកដ្ឋានសាសនា និង សាសនិកនៃវិហារឥស្លាមភូមិកំពង់ កណ្តាល ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦.- សេចក្តីសំរេចនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ហៀង វណ្ណារ័ត្ន

* * *

បោះពុម្ពនៅរោងពុម្ពធីស្ពិការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

[illegible] ១៨១០ [illegible]